## ចំពូកទីបី

ព្រះបិតានៃជីវភាព បានយាងចាកព្រះទែនបន្ទំបញ្ចេញរង្សីរុងរឿងត្រចះឯអាកាសវេហាស៍ទៀតហើយ ។ នាយរក្សាបុត្រសេដ្ឋីក្រោកចាកទីនិទ្រា រៀបចំខ្លួនចុះទៅបរបាញ់សត្វទៀត ប៉ុន្តែគេទៅម្តងនេះរីករាយចិត្តលើសម្តងមុន ត្បិតបានអនុញ្ញាតិពីឪពុក ម្តាយឱ្យស្វែងរក នាងក្រមុំនៅក្នុងព្រៃនោះនាំយកមកតាមបំណងចុះ ។ មិនតែប៉ុណ្ណោះ សេដ្ឋីឪពុកបានឱ្យមាសជាច្រើនសន្លឹក ដើម្បីជាមធ្យោបាយយ៉ាង ងាយក្នុងការលួងលោមចិត្តអ្នកក្រឱ្យបាក់តាម ។



រក្សាចាប់ចេញដំណើរដោយសេះឱ្យឆាប់ដល់ ឥតរវល់មើលអស់ម្រឹគដែលនៅក្បែរៗខ្លួនផងទេ ។ គេគិតតែស្រូតដំណើរឱ្យដល់ឆាប់ៗ

ចំណោទភ្នំបណ្តាលឱ្យពិបាកនឹងពុះពារប្រវាឡើងព្រៃលែង ប៉ុន្តែជំនិះរបស់រក្សា នៅតែខំស្រូតស្រះតាមចិត្តបង្ខំរបស់គេឥតបង្អង់ដោយនឿយណាយអ្វីឡើយ ។

ព្រះអាទិត្យជិតត្រង់ទៅហើយ ទើបបុរសនេះដល់ខ្ទមនាយគង្វាលពីម្សិលមិុញ ។ គេចុះពីខ្នងសេះពីចំងាយបន្តិច ហើយលែងសេះសាំងនេះឱ្យស៊ីស្មៅតាមចំណង់ រួចខ្លួនគេក៏ដើរមួយៗចូលទៅក្បែរខ្ទមស្រាប់តែប្រទះឃើញនាងភូងម៉ាឡៃកំពុងបុកអង្ករតែម្នាក់ឯងក្រោមដើមជើងចាបខាងក្រោយខ្ទម ។

_នាង!លោកមាអញ្ជើញទៅណាហើយ ?

_កាលឮសំលេងប្រុសសួរដូច្នេះកញ្ញាភ្ញាក់ព្រើត ងាកផាំងមក ទើបបុរសនេះនិយាយទៀត

_នាងនៅចំណាំខ្ញុំទេ ? ខ្ញុំនេះហើយដែលជិះសេះមកដល់លំនៅនាងពីម្សិលមិុញនោះ

_ចុះឥឡូវនេះលោកអញ្ជើញមក នេះមានការអ្វីទៀត

ហើយ?

-បាទ ! ខ្ញុំមកចង់ជួបលោកមាពិគ្រោះការបន្តិច

-ចាំះ បើលោកចង់ជួបនឹងឪពុកខ្ញុំ សូមអង្គុយរងចាំបន្តិចទៅ គាត់ទៅឃ្វាលគោមិនទាន់មកទេ លុះតែថ្ងៃត្រង់ជាក់ទើបគាត់ត្រឡប់មកវិញ!

-ចុះនាងនៅតែឯងមិនខ្លាចទេឬក្នុងព្រៃស្ងាត់យ៉ាងនេះ?

-ចាំះមានទៅខ្លាចអី បើខ្ញុំធ្លាប់តែនៅស្ងាត់រាល់ថ្ងៃទៅហើយ!

-យី. ប្រសិនជាខ្ញុំវិញ មុខជាអផ្សុកល្ហោចហើយអីស្ងាត់ដូច្នេះ!

-នោះលោកធ្លាប់នៅទីក្រុងចុះខ្ញុំធ្លាប់តែយ៉ាងនេះទៅហើយមានទៅរវល់អីនឹងការស្ងាត់នោះ!

-ប៉ុន្តែនៅក្នុងព្រៃសប្បាយម្យ៉ាងដែរ ព្រោះសំបូរណ៍ផ្លែឈើឆ្ងាញ់ៗ ហើយសប្បាយនឹងស្តាប់សំរែកសត្វណាស់ផងមែនទេនាង?

-ចាំះ ថាឯចឹងក៏សមដែរ ព្រោះវាត្រូវនឹងខ្ញុំអ្នកសាត់ព្រាត់ទីទាល់ក្រ ប្រសិនបើខ្ញុំមានទ្រព្យទូលំទូលាយដូចគេប្រហែលជា



ខ្ញុំមុខជាបានប្រទះទីក្រុងដែរទៅហើយ !

-មិនអីទេនាង បើនាងចង់ផុតពីទីនេះ ខ្ញុំមានចិត្តរីករាយជាទីបំផុតនឹងអញ្ជើញនាង. និងលោកមាទៅនៅឯទីក្រុង ផ្ទះខ្ញុំមានសន្ទឹកណាស់សំរាប់ទទួលភ្ញៀវ(និយាយផងសើចផង ឯភ្នែកបេះតែដោតទៅចំរូបនាងក្រមុំ)... ផ្ទះខ្ញុំធំ ៗ ទូលាយណាស់...

-សូមលោកកុំបារម្ភឱ្យសោះ ខ្ញុំនិយាយនេះមិនមែនដោយចេតនាចង់ឱ្យលោកអញ្ជើញខ្ញុំទៅទាំងអស់គ្នាដូចលោកថាអម្បាញ់មិញនេះទេ

-មិនដូច្នេះទេនាង ខ្ញុំឃើញរូបរាងដៃជើងនាងមិនសមនៅក្នុងព្រៃធ្វើការដោយកំលាំងដូច្នេះសោះ បានជាខ្ញុំចង់អញ្ជើញនាងទៅនៅទីក្រុង

-សូមលោកអង្គុយសិន ខ្ញុំទៅដងទឹកដាក់ពាងបន្តិច(ថារួចនាងទាញក្រួសមួយគូដើរទៅ )

-នាង! នាងទៅដងទឹកដល់ណា? ឆ្ងាយឬជិត ។

-មិនឆ្ងាយប៉ុន្មានទេលោក ទឹកជ្រោះនៅជិតនេះទេ

-ចាំខ្ញុំជូនទៅឬ កុំឱ្យខ្លាច !

-ចាំះ កុំព្រួយផ្លូវនេះខ្ញុំធ្លាប់ដើររាល់ថ្ងៃទៅហើយ

កាលបើសុំខ្លួនជូននាងមិនបានហើយ វត្សានៅអង្គុយក្រោមដើមឈើតែម្នាក់ឯង តាមមើលដំណើរនាងដែលកាន់តែឆ្ងាយ ៗទៅ ។

មួយសន្ទុះ វត្សាក៏ស្ទុះទៅផែលលើខ្នងសេះ រួចបំផាយទៅតាមផ្លូវដែលនាងក្រមុំដើរទៅមុន ។ សេះបោលយ៉ាងលឿនមួយភ្លែតប៉ុណ្ណោះបានទៅទាន់ភ្លាម ដែលនាងកំពុងតែផ្លាស់សំលៀកបំពាក់ចុះងូតជម្រះកាយ ក្នុងប្រឡាយទឹកជ្រោះ។ នាងភ្ញាក់ព្រើតកាលបានឃើញរូបប្រុសកំឡោះប្រាកដឡើងនៅក្រោយខ្នង ។

យីកន្លែងទឹកនៅជិតសោះ ខ្ញុំស្មានតែនៅឆ្ងាយណាស់ ទឹកថ្លាឆ្វង់ប្រហែលត្រជាក់ល្អណាស់ឬនាង?

កាលណានាងឮសួរសំដីនេះភ្លាម ក្នុងកាយនាង ហាក់បីដូចជាមានគ្រឿងចក្រអ្វីមួយមករណ្ដំញាប់ញ័រឥតអាក់ នាំឱ្យនាងស្រឡាំងកាំងរកពាក្យឆ្លើយតបនឹងប្រុសនោះមិនរួចឡើយ

-យីទឹកនេះថ្លាណាស់ហ្ន៎!(វត្សា បន្តសំដីគ្រាដែលឃើញនាងកញ្ញានៅស្ងៀម ) មើលចុះឆ្លុះឃើញសព្វទាំងដុំគ្រួសមានពណ៌ផងនៅ បាតស្ទឹងនេះ !



-ចាំះ! ទឹកកន្លែងនេះ តែងតែថ្លាខួបប្រាំង, ខួបវស្សាអញ្ចេះឯង

-ចុះនាងដឹងទេ ទឹកនឹងហូរចេញពីកន្លែងណាមក ? មាននរណាដែលប្រទះមេទឹកនេះទេ ?

-ចាំះ តាំងតែពីខ្ញុំមកនៅលើភ្នំ ឥតដែលឮនរណានិយាយពីកន្លែងជាដើមកំណើតនេះទេ ។

-យី! គ្រួសដែលនាងកាន់មកដងទឹកនេះ នាងបានពីណាមកនៅស្រុកនេះគេមានលក់ឬ ?

-ចាំ ឥតមានលក់ទេ គេធ្វើគ្រាន់តែប្រើប្រាស់រៀងខ្លួននេះឯង! របស់ខ្ញុំនេះលោកពុកខ្ញុំចាក់ដៃឯងទេតើ ។

-អូ! លោកមាប្រសប់មែនហ្ន៎! ប៉ុន្តែបើខ្ញុំសង្កេតទៅលោកមាមិនសមជាអ្នកឃ្វាលគោ, ជាអ្នកត្បាញល្អីកញ្ជើ ឬជាអ្នកចាក់គ្រួសនេះសោះ ។

-ម៉េចក៏លោកថាមិនសម ? បើគាត់ជាអ្នកស្រុកព្រៃស្រុកភ្នំគាត់មានរួញរាអីនឹងការលំបាកដូច្នេះ !

-គាត់មិនរួញរាមែន តែខ្ញុំចង់អញ្ជើញគាត់ឱ្យទៅនៅទីក្រុងជាមួយខ្ញុំ ខ្ញុំមិនឱ្យគាត់ធ្វើអ្វីទាំងអស់គ្រាន់តែសំរាន្តលេង

សំរាកកាយ ជាមួយតែនាងអូនទៅបានហើយ ។ អូ! អត់ទោស ខ្ញុំហៅដោយឥតសុំអនុញ្ញាតអំពីនាងជាមុនសោះ តែណ្ហើយឱ្យខ្ញុំហៅនាងអូនចុះ ត្បិតហៅនាងទទេៗដូចជាមិនសមមែនទេ ?

-ចាំះ ឥតទាស់សោះលោក!

-ឈប់ ៗ ! សុំនាងអូនកុំហៅខ្ញុំថាលោកៗដូច្នេះ ដ្បិតខ្ញុំឥតមានងារសក្តិអ្វីក្នុងទីនេះទេ គ្រាន់តែមានអាយុច្រើនជាងបន្តិចប៉ុណ្ណោះ

-អញ្ចឹងលោកចង់ឱ្យខ្ញុំហៅអី ? ខ្ញុំអ្នកព្រៃមិនប៉ិនប្រសប់ហៅសោះ ណ្ហើយហៅបងៗចុះ តែដូចជាមិនគួរទៀតសុំបន្ថែមថា "លោកបង" ចុះល្មមទេ !

-ល្មមហើយនាងអូន ! ល្មមហើយ . . .

នាងភួងម៉ាឡៃសើច រួចក៏ជ្រមុជត្រួសទៅក្នុងទឹក យូរឡើងមកដាក់លើគោកម្តងមួយ ទើបតែយូរបានមួយ នាយរត្សាក៏ប្រញិបប្រញាប់យូរមួយទៀតមកជំនួសនាងភ្លាម :

-កុំលោកបង  កុំយូរអីនាំតែទទឹកខោទេ, ទុកឱ្យខ្ញុំយូរបានហើយ . . .

-កុំព្រួយនាងអូន  បងចូលចិត្តណាស់ធ្វើការយ៉ាងនេះ



លាក់បាំងអ្វីនាងអូន សព្វថ្ងៃមានតែម្នាក់ទេដែលចេះតែអួតពីទីក្រុង បើតាមក្នុងចិត្តពិតនោះមិនមែនទេខ្ញុំស្អុះស្អាប់បំផុត ហើយអាការៈនៅទីក្រុងនោះ ខ្ញុំចូលចិត្តលេខមួយតែនឹងទេសភាពព្រៃភ្នំ, ទេសភាពស្រុកខ្មែរយ៉ាងហ្នឹង!

-ណ្ហើយកុំបញ្ជោរលោកបង វាទៅល្អអីទេសភាពព្រៃស្មុគស្មាញដូច្នេះ !

-នាងអូនមើលអាកាសស្អាតផង, ខ្យល់បក់ត្រសៀកស្លឹកឈើយោលយោគរកគ្នា មើលចុះ! ខ្យល់មិនត្រឹមតែបក់ស្លឹកឈើទេ បំប៉ើងដល់សក់នាងអូនទៀត ល្អមើលណាស់ហ្ន៎ សក់នាងអូនចេះរត់ប្រលែងគ្នា

-លោកបងមិនដឹងជាស្អីទេ  សក់ណាចេះប្រលែងគ្នា?

-ចុះនាងអូនមិនមើល! ហ្ន៎ឃើញទេ កំពុងត្រសុលតាមខ្យល់ ហើយត្រូវនឹងសក់នាងអូនសផងសមគ្នាណាស់ហ្ន៎ សក់ខ្មៅញាប់យ៉ាងហ្នឹង, បបូរមាត់ក៏ក្រហមស្រស់, ធ្មេញក៏សលោង, សើចឡើងញញឹមសម !

-មិនចង់តសំដីសោះលោកបង ! នាំតែពាក្យវែង ។

-អូ ! អូ !  នាងអូនមើលមានរូបស្រីម្នាក់ដូចនាងឯចឹង

នៅក្នុងទឹក !

-ឯណាមិនឃើញ ?

-នុះ ! នុះ ញ័រទ្រើក ១ តាមកូនរលក

-អី! មានមនុស្សឯណា ស្រមោលខ្ញុំទេតើ !

-យី ! ស្រមោលនាងអូនទេ ? ខ្ញុំស្មានតែរូបទេព្ធានិមិត្ត មួយទៀតលោកអើយ ។

-ណ្ហើយ លោកបងនៅអង្គុយលេងតែឯងចុះ ខ្ញុំប្រញាប់យកទឹកទៅដាំបាយ ។

-អីក៏បន្ទាន់ម្ល៉េះ ? និយាយលេងមិនទាន់អស់ចិត្តផង ប្រញាប់ទៅណាភ្លាម ?

-ទេលោកបង ជិតដល់ពេលលោកពុកខ្ញុំត្រឡប់មកផ្ទះហើយ ប្រហែលជាគាត់មកផ្ទះហើយក៏មិនដឹង ។

ថារួចនាងកញ្ញាខ្នងភ្នំ ស្ទុះម្នីម្នាជម្រង់ទៅលំនៅនាងវិញជាបន្ទាន់ ដ្បិតនាងនឹកដល់ពេលបាយរបស់ឪពុក ហើយម្យ៉ាងទៀតតាំងពីកើតមក នាងមិនដែលអង្គុយសន្ទនាជាមួយប្រុសកំឡោះឯណាឱ្យអស់ពេលយូរដល់ម្ល៉េះទេ . . .

ឈប់សិននាងអូន ឈប់សិន ! ខ្ញុំភ្លេចសួររកវត្ថុ



មួយដែលនាងអូនយករបស់ខ្ញុំទៅ ។

-ទេ, ខ្ញុំមិនដែលយកវត្ថុអ្វីសូម្បីបន្តិចបន្តួចទេ របស់លោកបងនោះ

-ម៉េចក៏នាងអូនថាមិនដែលយក នាងអូនភ្លេចហើយឬកាលទៅងូតទឹកត្រង់កន្លែងទឹកធ្លាក់, ផ្កាមួយទងរបស់ខ្ញុំដែលបណ្តែតទៅ ហើយនាងអូនរើសយកនោះ ឥឡូវទៅណាទៅ?

-ទេ! ខ្ញុំចាំមិនបានទេ កាលនោះខ្ញុំគិតតែភ័យព្រោះភ្ញាក់នឹងរូបប្រុសម្នាក់ មានទៅរវល់អីនឹងផ្កាមួយទងនោះ

-យី! ម៉េចក៏ឱ្យបាត់ផ្កាខ្ញុំ នាងអូនដឹងថាខ្ញុំប្រាថ្នាយ៉ាងណាខ្លះជាមួយផ្កានោះ ?

-ខ្ញុំមិនដឹងជាប្រាថ្នាអ្វីទេ ប៉ុន្តែខ្ញុំភ័យ ខ្ញុំបោះបណ្តែតចោលតាមទឹកទៅ !

-ឥឡូវនាងអូន ចង់ដឹងសេចក្តីប្រាថ្នាជាមួយផ្កានោះថាម្តេចៗ ទេ !

-បើពិត, ខ្ញុំមិនចង់ដឹងសោះ ព្រោះមិនជាការសម្រាប់រូបខ្ញុំទេ !

-ទុកជានាងអូនមិនចង់ដឹង ក៏ត្រូវតែខ្ញុំរ៉ាយរ៉ាប់ឱ្យនាងអូនស្តាប់ដែរ  កុំឱ្យមានសង្ស័យទៅថ្ងៃក្រោយទៀត ។

-បើលោកបងមានពេលនិយាយ  ក៏និយាយទៅ តែខ្ញុំដូចជាឆ្ងៀតនៅស្តាប់មិនបានទេ ។

-មេត្តាលៃពេលនៅស្តាប់បន្តិចចុះ... កាលនោះខ្ញុំប្រាថ្នាថា បើនារីណាបានផ្ការបស់ខ្ញុំ នារីនោះឯងត្រូវជា..!

-ត្រូវជាអ្វី ?

-ត្រូវជាគូព្រេងនឹងខ្ញុំ ។ ឥឡូវនេះនាងអូនរើសបានតើនាងអូនយល់ថាម៉េច !

-ខ្ញុំយល់ថាជាការធម្មតា  ព្រោះផ្កាខ្ញុំរើសបានក្នុងទឹកខ្ញុំស្មានតែជ្រុះពីដើមវាហើយអណ្តែតមក ប្រសិនជាខ្ញុំដឹងថា លោកបងបេះបណ្តែតមក  ខ្ញុំមិនដៀតយកដៃពាល់ទេ ។

-នាងអូនអីក៏ស្អប់ខ្ញុំម្ល៉េះ  ខ្ញុំមានវត្ថុតម្លៃឯទៀតសម្រាប់បំពេញបំណងនាងអូនហ្នាំ ដូចយ៉ាងមាសពេជ្រដ៏ល្អៗ (ថាផង វត្សាលូកយកមាសពីក្នុងហោប៉ៅអាវមកបង្ហាញ) ។

-ហ៊ឺ ! . . . ដល់ម្លឹងលោកបង . . . រូចមនុស្សម្នាក់ៗ



លោកបងស្មានថាមានតែសម្បត្តិមាសពេជ្រនេះហើយ ឬដែលធ្វើឱ្យប្រសើរនោះ ?

-ពិតមែននាងអូន !

-សម្បត្តិមាសពេជ្រជាទ្រព្យរកបានក្រោយទេ សូមលោកបងកុំច្រឡំ...

ថាតែប៉ុណ្ណោះ នាងក្រមុំខំលើកដងរែកឡើងដាក់លើស្មា តែវត្សាស្ទុះមកកញ្ឆក់យកអម្រែកទឹកពីស្មានាង មកដាក់ស្មាខ្លួនឯងវិញហើយដើរលឿនស្លុងទៅ :

-កុំធ្វើដូច្នេះលោកបង ! លោកបងមិនដែលរែកទេ ទុកឱ្យខ្ញុំវិញ!

-កុំព្រួយនាងអូន !  ចំពោះនាងអូនទុកជាទឹកពីរអម្រែកក៏ខ្ញុំរែកបានដែរ . . .

-ដល់ម្លឹងហ្នំ !

វត្សាពោលជាមួយនាងហើយ គេក៏ឥតបង្អង់ជើងឡើយ គេដើរលឿនស្លុងតម្រង់ទៅលំនៅរបស់នាង ។ ចំណែកភួងម៉ាឡៃ នាងឥតត្រេកអរសោះចំពោះការដែលគេមកជួយរំលែកទំងន់ពីនាងនេះដោយនាងយល់ថា " ប្រសិនជាវត្សារែកទឹកទៅ

ដល់ផ្ទះនាងមុន ហើយជួបនឹងឪពុកនាងនៅនោះ មុខជាឪពុកនាងស្មានថាខ្លួននាងនឹងបុរសនេះ មានអីជាប់ជំពាក់ចិត្តថ្មើមអ្វីនឹងគ្នាជាការខុសគន្លងប្រពៃណី និងជំបូន្មានឪពុកមិនខាន" ។ ដោយគិតឃើញដូច្នេះ នាងខំរូតរះម្ទីម្នាដើរឱ្យទាន់អ្នកកំឡោះរក្សាដែលកំពុងទ្រាំស្សែកនឹងទម្ងន់ទឹកមួយម្រែក ផ្សិតតាំងពីកើតមកមិនដែលទៅធ្វើអ្វីឱ្យធ្ងន់ដល់ម្លឹងទេ ។ ឱហ្ន៎ !សេចក្ដីស្នេហាចេះប្រើមនុស្សបានគ្រប់បែបគ្រប់យ៉ាង តើស្ដេចនៃសេចក្ដីស្នេហាគង់នៅស្ថានណា បានជាមានអានុភាពដ៏មហស្ចារ្យម្ល៉េះ?

ជូនជាភព្វ័ល្អ, រក្សារែកទឹកទៅដល់ផ្ទះហើយក៏ឥតឃើញមានអ្នកណាម្នាក់នៅនោះសោះក៏យកទឹកទៅដាក់កន្លែងស្រួលទើបថយមកអង្គុយនៅរបៀងផ្ទះខាងមុខ ដើម្បីបំបាត់ការហត់នឿយ ។ នាងកញ្ញាមកដល់ភ្លាម ក៏រត់ចូលទៅរៀបចំអិនម្ហូបតាមធម្មតា ទុកឱ្យរក្សាអង្គុយតែម្នាក់ឯងឱ្យសមរម្យជាភ្ញៀវផងទាំងពួង។

មួយភ្លែតប៉ុណ្ណោះ តាគង្វាលបាននាំហ្វូងគោតម្រង់មកចូលក្រោលភ្លាម ។ តែពេលនោះព្រះអាទិត្យនៅខ្ពស់នៅឡើយគាត់ក៏លែងពាហានៈគាត់ឱ្យនៅខាងក្រៅសិន ចំណែកខ្លួនគាត់ដើរលឿនស្លុងចូលមកលំនៅ :



-ជំរាបសួរលោកមា (រក្សាគោរពម្ចាសផ្ទះគ្រាដែលគាត់ចូលមកដល់មាត់ទ្វា )

-អី គួរសមក្មួយ ! ក្មួយមកយូរហើយឬ ?

-បាទមកដល់មួយសន្ទុះធំហើយ !

-អី មកម្ដងនេះមានការអីទៀតហើយ ?

-បាទ ! មានការផ្ទាល់ជាមួយលោកមា

-ការអីទៅអេះ ឯងមិនដឹងខ្លួនសោះ ការធំឬតូចក្មួយ

-សូមលោកមាឈប់សំរាកបន្តិចសិនទៅ ចាំខ្ញុំជំរាបជាក្រោយ

-តាគង្វាលប្រញិបប្រញាប់ ដោះសំលៀកបំពាក់ព្រៃហើយដើរចូលទៅផ្ទះបាយមើលកូនស្រីគាត់ :

-ភួងម៉ាឡៃ ទឹកក្ដៅពុះហើយនៅកូន ?

-ចា៎ះ ពុះយូរហើយលោកពុក ខ្ញុំឆុងដាក់ប៉ាន់ទុកជូនជាស្រេច( ថាផងនាងចង្អុលបង្ហាញឪពុកផង) ។

-ក្រោយដែលបានឮកូនប្រាប់រួច តាយើងគាត់បែរមកក្រៅទាញប៉ាន់តែមកដាក់ភ្លាមរួចចាក់ដាក់ពែង :

-អញ្ជើញពិសារទឹកក្ដៅក្មួយ !

-បាទកុំព្រួយលោកមា !

-យី ពិសារទៅ ! នឹងអាលនិយាយការអីដែលក្មួយត្រូវការនោះ ។

បុរសចាស់ នឹងក្មេងទាំងពីរនាក់លើកពែងទឹកក្តៅឡើងអាស្រ័យស្មើគ្នា លុះអស់ទើបដាក់ចុះវិញ ទើបវក្សាចាប់និយាយមួយ ៗ រាងញញើតញញើម ១ :

-អត់ទោសលោកមា ! ការដែលខ្ញុំនឹងនិយាយឥឡូវនេះដូចជាមិនគប្បីតែសុំលោកមាអត់ទោសជាមុនសិន ។

-កុំព្រួយក្មួយ យើងអ្នកព្រៃអ្នកផ្សៃដូច្នេះ មិនសូវចេះប្រកាន់ខឹងទេ ។

-បើលោកមាអត់ទោសឱ្យខ្ញុំ ខ្ញុំនឹងជំរាបជាហូរហែទៅ

-អីនិយាយមកចុះ មាមិនថាអីទេនិយាយចុះ ! វក្សាហាមាត់និយាយដោយសំដីមិនសូវលះ ឯភ្នែកឱនជ្រប់សំឡឹងប៉ាន់តែហើយកន្ទុយភ្នែកលួចគន់ទឹកមុខ តាម្ចាស់ផ្ទះម្តង១ដែរ :

-តាំងពីខ្ញុំបាទមកដល់លំនៅលោកមា ហាក់ដូចជាមានអារុក្ខទេវតាអង្គណាមួយទាញសតិខ្ញុំ ឱ្យនឹកមមៃឱ្យចង់តែមក



ជួបនឹងលោកមាទៀត ហើយខ្ញុំនឹកចង់ជ្រកកោនក្រោមម្លប់សុភមង្គលរបស់លោកមាថែមទៀត !

-អូក្មួយអើយ !មាទៅមានសុភមង្គលអ្វីសំរាប់ក្មួយចូលជ្រោកកោននោះ បើនៅកណ្តាលព្រៃយ៉ាងហ្នឹង ។

-ពិតមែនតែកណ្តាលព្រៃ ប៉ុន្តែសុភមង្គលរបស់លោកមា មានជានិច្ចសម្រាប់រូបខ្ញុំ ។ តាំងតែពីត្រឡប់ទៅដល់ផ្ទះខ្ញុំវិញភ្លាម ខ្ញុំសុំអង្វរលោកពុក-អ្នកជាយខ្ញុំ ឱ្យអញ្ជើញមកជួបនឹងលោកមា ដើម្បី... ដើម្បីស្តីដណ្តឹងនាងអូនជាកូនលោកមា !

-អូ! ក្មួយអើយ, បុត្រីអ្នកក្រុងគគោក ក្មួយទៅប្រាថ្នាអីរូបស្រីស្រុកព្រៃដូច្នេះ, ហើយមាក្រីក្របំផុត ទៅរកសេចក្តីថ្កុំថ្កើងឱ្យក្មួយឯណាបាន ។

-ពិតមែនតែមាក្រ ឯសេចក្តីសុខសំរាន្តលោកមាមិនចេះខ្វះ ដ្បិតខ្ញុំមិនត្រូវការនឹងអ្នកថ្កុំថ្កើង ហើយមានសម្បត្តិទៀតទេ ព្រោះវត្ថុទាំងនេះគ្រួសារខ្ញុំមានបរិបូរណ៍អស់ហើយ ។ លោកមាក៏គង់ដែលឮខ្លះដែរ លោកសេដ្ឋីសុដ្ឋាជាបិតាខ្ញុំ ។

-ឱ! មាធ្លាប់ឮឈ្មោះដែរ លោកសេដ្ឋីនេះលោកមានមែន មិនសមជាដន្លងនឹងមាជាអ្នកខ្សែខ្សោកដូច្នេះទេក្មួយ ។

-ឥតទាស់សោះលោកមា . . លោកមា! ពេលនេះលោកពុកនិងអ្នកម្ដាយខ្ញុំមានកិច្ចរវល់ ហើយម្យ៉ាងទៀតដោយផ្លូវពិបាកផង គាត់មិនបានធ្វើដំណើរមកទេ គាត់ឱ្យខ្ញុំមកតែម្នាក់ឯងព្រម ទាំងនាំយកពាក្យបណ្ដាំដែលជាសេចក្ដីស្ដីដណ្ដឹងមកសុំអង្វរលោកមាដោយមេត្រីភាព សូមកុំឱ្យលោកមាប្រកាន់អាក់អន់ចិត្តឡើយ!

-មាមិនប្រកាន់ទេក្មួយ ចូរក្មួយជំរាបលោកវិញចុះ តែមាដូចជា,

-លោក ! លោកពុកមិនត្រឹមតែប្រើខ្ញុំមកដោយទទេនោះទេលោកបានទាំងផ្ញើមាសជាច្រើនសន្លឹកមកធ្វើជាបណ្ណាការផង (វត្សាហូតមាសចេញពីក្នុងហោប៉ៅមកបង្ហាញតាគង្វាល) រួចលោកផ្ដាំនឹងខ្ញុំទៀតថា ប្រសិនបើលោកមាព្រមព្រៀងហើយ សូមអញ្ជើញលោកមានឹងនាងអូនទៅនៅឯទីក្រុង ដ្បិតគាត់បានរៀបចំលំនៅមួយយ៉ាងទូលាយសម្រាប់ជូនជាស្រេច !

-ក្មួយ ! មាត្រេកអរណាស់ដែលឃើញក្មួយជាអ្នកមានសម្បត្តិហើយមករាប់អានខ្លួនមាដូច្នេះ តែសូមក្មួយអត់ទោសដល់មាវិញចុះ មាចង់សួរថាតើក្មួយនេះសព្វថ្ងៃប្រកបការអ្វី, មានមុខងារ



ជាអ្វី, មានវិជ្ជាអ្វីសំរាប់ប្រចាំជីវិតទេ ?

-អត់ទោសលោកមា, ខ្ញុំមិនបានរៀនសូត្រវិជ្ជាអ្វីជ្រៅជ្រះទេ គឺឥតបានធ្វើមន្ត្រីក្នុងរាជកា ឬធ្វើរបរជំនាញជាជាងអ្វីមួយឡើយ ដ្បិតតាំងពីខ្ញុំធំដឹងក្ដីមក រវល់តែជួយរៀបចំផ្ទះសំបែង ត្រួតត្រាមើលសម្បត្តិទ្រព្យក្នុងផ្ទះ តែខ្ញុំមិនបាច់ទៅព្រួយពេកទេ ដូចជាលោកមាជ្រាបស្រាប់សម្បត្តិបរិបូរណ៍ដូចលោកពុកខ្ញុំ ហើយមានកូនតែរូបខ្ញុំមួយ តើយកទ្រព្យទៅណាអស់ឱ្យខ្ញុំថ្កុំថ្កើងមួយជីវិតមិនបានឬ ?

-ថ្វីក៏មិនបានក្មួយ, ប៉ុន្តែចូរក្មួយជ្រាបថា : រូបមនុស្សប្រុសម្នាក់ៗ ត្រូវតែមានវិជ្ជាអ្វីមួយប្រចាំជីវិតទើបប្រសើរ ។ ព្រោះសម្បត្តិទ្រព្យ ជាវត្ថុអាចរលាយទៅវិញបាន នៅពេលណាមួយឯចំណេះវិជ្ជាវិញ មិនអាចមានពេលកម្រើតនឹងអន្តរធានបានមុនយើងអស់ជីវិតឡើយ ។ ចូរក្មួយយល់ថា វិជ្ជាជាតម្លៃបំផុតជាខ្លឹមសាររបស់ជីវភាពមនុស្សប្រុស សូម្បីតែវិជ្ជាជាងទង, ជាងឈើ, ជាងស្មិត ឬជាង អ្វីទាំងពួងក៏គួររាប់ថាជាវិជ្ជាសំខាន់ដែរ ។ ព្រោះមនុស្សជំពូក នេះគេមិនសូវបារម្ភចំពោះការស្វែងរករបរលៀងជីវិតគេ និងគ្រួសារគេទេ ទុកជាសាត់ព្រាត់ទៅដល់ទិសទីណាក៏ដោយ។

ទីបំផុត ចូរក្មួយចាំថាមនុស្សប្រុសឥតមានវិជ្ជាប្រចាំកាយ ប្រៀបបាន ទៅនឹងទូកក្ដោងដែលត្រូវខ្យល់ ហើយមិនបាច់ពឹងកំលាំងចែវច្រវា លុះដល់គ្រាជាទេសកាលអ្វីបណ្ដាលឱ្យខ្យល់ស្ងប់ឈឹងទៅ ទូកនេះ ឯងនឹងឡេឡា រកជម្រង់កោះត្រើយឯណាពុំមានសង្ឃឹមទាំងអស់ គឺបណ្ដែតតាមវាសនាតែម្ដង ។ ចុះប្រសិនណាជាយើងរៀបបំរុង ស្រេចទាំងចែវច្រវាទុកជាឥតខ្យល់សោតក៏យើងឥតរវល់ ឬ ក៏ឥត ទាំងក្ដោងទៀតក៏បាន ព្រោះចែងច្រវានេះអាចនាំទូកយើងឱ្យទៅ ដល់ត្រើយបានដោយងាយ ។

-លោកមាកុំទៅគិតអីវែងឆ្ងាយពេកនាំតែរារែកចិត្តឥត អំពើទេ មាសរបស់ខ្ញុំទាំងសន្លឹកៗនេះ អាចជួយដោះទុក្ខលោកមា បានយ៉ាងងាយ មិនបាច់ពិបាកនៅកណ្ដាលព្រៃផ្សូច្នេះផង

-អូ! ក្មួយអើយ, មាសប្រាក់នេះឯងជាគ្រឿងបោក បញ្ឆោតទឹកចិត្តអ្នកខ្សត់ខ្សោយងាយបំផុត តែចំពោះរូបមាឥតរំភើប ចិត្តដោយសារសន្លឹកមាសនេះឡើយ ក្មួយមិនគួរយកនុយដែលគ្មាន ខ្លឹមសារដូច្នេះមកបង្ហាញមាទេ !

-អត់ទោសលោកមា ! ដោយសារចេតនារបស់ខ្ញុំដែល ប្រាថ្នាមកអញ្ជើញលោកមាទៅនៅឯទីក្រុងនឹងគេ ទើបខ្ញុំមកសុំ



នាងអូនធ្វើជីវិតឱ្យបានរុងរឿងតទៅមុខនេះ ហើយខ្ញុំហ៊ានធានាថា: នឹងធ្វើឱ្យលោកមានឹងនាងអូនបានសប្បាយចិត្តអស់រហូតមួយជីវិត។

-ក្មួយ! កូនស្រីមា, មាចិញ្ចឹមមកសំរាប់តែរៀបឱ្យមាន គូស្រករមែនពិតហើយ មិនមែនចិញ្ចឹមមកទុកឱ្យបំរើមួយជាតិនោះ ទេ ប៉ុន្តែមាត្រូវការឱ្យទៅលើជនណា ដែលមានវិជ្ជាប្រចាំជីវិតដើម្បី ឱ្យកូនមាផុតពីតោកយ៉ាកដោយទេសកាលម្ដងៗ ។ ហេតុនេះ មា សូមបញ្ជាក់ជំរាបក្មួយឱ្យច្បាស់ថា កូនស្រីមានេះមិនប្រាថ្នារើសយក តែស្វាមីណាមានរូបសម្ប៉ទ នឹងភោគសម្ប៉ទឡើយ គឺត្រូវការតែ បុរសណាមានវិជ្ជាសម្ប៉ទប៉ុណ្ណោះ បើក្មួយចេះធ្វើម៉េចឱ្យតែរៀន ចេះវិជ្ជាអ្វីមួយដោយមានភស្ដុតាងមកចុះ មានឹងសុខចិត្តប្រគល់កូន នេះជូនភ្លាម សូម្បីវិជ្ជានោះតូចទាបយ៉ាងណាក៏ដោយ ឱ្យតែចេះទាង ទាត់ពិតប្រាកដ ។

រត្សាដាក់កញ្ចប់មាសក្នុងហោប៉ៅវិញ រួចអង្គុយជ្រប់ មុខ ខ្មាស់ដល់តាគង្វាលតែមិនចេញស្ដីមួយមាត់សោះ ។ លុះល្ងាច កាន់តែទាបណាស់ទៅហើយ ទើបតាម្ចាស់ផ្ទះស្រែកហៅកូនស្រីឱ្យ លើកបាយយកមកពិសារជាមួយភ្ញៀវដែលពេលនេះអាស្រ័យផង និយាយគ្នាលេងពីការផ្សេងៗផង :

-យប់នេះក្មួយមិនបាច់ត្រលប់ទៅផ្ទះវិញទេ នៅសំរាក លេងនឹងមានេះមួយយប់សិនទៅ

ក្រោយពីកិច្ចសន្ទនាគ្នាជាយូរ បុរសទាំងពីនាក់ក៏ចូល និទ្រារៀងខ្លួន តែវត្សានៅមិនលង់លក់សោះ ចេះតែគិតមិនដាច់មិន ស្រេចក្នុងចិត្ត ដោយសេចក្ដីបំណងរបស់គេមិនបានសម្រេចសោះ។ ឥឡូវនឹងគិតត្រលប់ទៅលំនៅវិញ នាំឱ្យខ្មាស់សំដីដល់មាតា-បិតា នឹងពពួកអ្នកនៅក្នុងផ្ទះ ហើយគោលបំណងមុខជាមិនបានសម្រេច ឡើយ ។

* * *

សូមរង់ចាំអានជាបន្តនូវរឿង:

" **ទឹកទន្លេសាប** " របស់អ្នកនិពន្ធ **គឹម ហារ៉** ដែលជា

ប្រលោមលោកបែបមនោសញ្ចេតនា នាទសវត្ស

ឆ្នាំ ១៩៣៩ ។ ដែលនឹងចេញផ្សាយពីបណ្ណាគារដដែល

ក្នុងពេលឆាប់ៗខាងមុខនេះ !!!



## ចំពូកទីបួន

ព្រះអាទិត្យមិនទាន់រះផង នាយវត្សាគោរពលាតា គង្វាលរួច លាទាំងនាងកញ្ញាភួងម៉ាឡៃទៀត ទើបផែលឡើងលើខ្នង សេះ បំបោលលឿនស្ទៅឥតរវល់គិតគូរអ្វីវែងឆ្ងាយឱ្យយឺតយូរឡើយ ម្ដងនេះគេមិនដម្រង់ទៅតាមផ្លូវដដែលទេ បែរឆ្ពោះមកខាងត្បូង វិញ ។ ពាហនៈរបស់វត្សាខំបោលបំពេញបំណងម្ចាស់ ឥតបានគិត ការនឿយហត់ នឹងផ្លូវលំបាកបន្តិចបន្តួចសោះ គិតយ៉ាងណាឱ្យតែ លឿន រហ័សបំពេញបំណងម្ចាស់ ។ វេលាថ្ងៃត្រង់ជាក់ទើបវត្សា បញ្ឈប់សេះឱ្យរកអាហារ ឯខ្លួនឯង ក៏រួតរះរកបេះផ្លែឈើយកមក បំបាត់ការស្រេកឃ្លានដែរ ។ ស្កប់ស្កល់ពោះបន្តិចហើយទើបរក

កន្លែងសំរាកកម្លាំង រហូតដល់ព្រះអាទិត្យយាងជ្រេបន្តិច ទើបចាប់បន្តដំណើរទៅទៀត។ អាជានេយ្យនៅតែខំបោលឥតបង្អង់ជើង លុះត្រាដល់ល្ងាចត្រជាក់ ស្រាប់តែប្រទះនឹងស្ទឹងមួយដែលមានឧបសគ្គនាំឱ្យដំណើរនេះឈប់រារង់បន្តិច ។ រត្សាលោតចុះពីខ្នងសេះ ដើរទៅឈរសម្លឹងទឹកស្ទឹង ពិនិត្យរកកន្លែងណាដែលជិតល្មមនឹងសេះឆ្លងបាន តែមកនឹកឃើញថាបើសេះកំពុងហត់ដង្ហក់យ៉ាងនេះ តើឱ្យហែលឆ្លងម្តេចរួច ដូច្នេះគួរតែឱ្យគ្នាឈប់សម្រាកឱ្យបាត់ហត់ស្រួលបួលសិន សឹមបន្តដំណើរទៅទៀត ។ សេះដើរបបេះបបោចចុងស្មៅខ្ចីៗ ដែលដុះនៅមាត់ស្ទឹង ឯរត្សានៅអង្គុយលើថ្មមួយផែន យកដៃឆ្វេងទ្រចង្ការ ដៃស្តាំកាន់រំពាត់មួយគ្រវីគ្រវាត់វាយចុងស្មៅលេង ស្រាប់តែឮសំឡេងជាងដំដែកប៉ុងបុាំងៗ តែស័ព្ទនេះនៅឆ្ងាយ ណាស់មិនអាចសន្និដ្ឋានចំងាយនៃទីកន្លែងនោះបានឡើយ។

-រត្សាក្រោកឈរស្តាប់យ៉ាងពិនិត្យនូវស្នូរស័ព្ទនេះមួយសន្ទុះធំ ទើបទាញសេះមកផែល ហើយគោះជើងជាសញ្ញាឱ្យសេះបោលលឿនទៅមុខ ។ សេះបង្ហំជម្រៀនអស់ទំហឹង លុះយូរបន្តិចទើបលេចឃើញចុងដំបូលផ្ទះអ្នកភូមិរកេតរកូត ឯស្នូរសព្ទ



ក៏កាន់តែខ្លាំងឡើងៗត្រាតែដល់ជាយភូមិ ទើបរត្សាលោតចុះពីខ្នងសេះ រួចដឹកសេះដើរដម្រង់កាត់ភូមិនោះ ។

-នែ៎! ក្មួយកំឡោះ ធ្វើដំណើរទៅណាមកណានេះចូលមកសម្រាកលេងសិន!(សំឡេងតាចាស់ម្នាក់រាងធាត់ក្រអាញអង្គុញច្រងក់នឹងមាត់ទ្វាផ្ទះ ស្រែកហៅអ្នកកំលោះយើង គ្រាដែលឃើញដើរកាត់មុខផ្ទះគាត់ ) ។

រក្សាបែរក្រោយ សម្លឹងទៅសំឡេងហៅ :

-បាទ! សូមអរគុណលោកតា... ថារួចរត្សាដើរចូលទៅជិតតានោះ លើកដៃសំពះសួរយ៉ាងគោរពតាមប្រពៃណីខ្មែរ !

-មកអញ្ជើញឡើងមក ! អាស្រ័យទឹកក្តៅកំសាន្តសិន! រត្សាចងសេះឱ្យស៊ីស្មៅមុខផ្ទះ រួចក៏ឡើងទៅតាមសេចក្តីអញ្ជើញរបស់តាអ្នកស្រុក ។

-ខ្ញុំបាទនៅស្រុកឆ្ងាយណាស់ ទើបតែមកដល់ភូមិនេះម្តងនេះ ហើយជាលើកដំបូង !

-អើក្មួយមកនេះត្រូវការទិញដូរអ្វី ! ឬមានការអ្វី ?

-លោកមា ! ខ្ញុំជំរាបដោយត្រង់ទៅចុះ ខ្ញុំមកនេះឥតប្រាថ្នាទិញដូរអ្វីទេ ខ្ញុំកាត់រករៀនវិជ្ជាខាងជាងដើម្បីប្រចាំជីវិតរបស់

ខ្ញុំ ។ បានជាខ្ញុំចូលមកកន្លែងភូមិនេះ ដ្បិតខ្ញុំស្ដាប់ពីចម្ងាយ ឮសូរគេដំអ្វីផ្ទូងផាំងៗ តើគេធ្វើជាអ្វីលោកមា ។

-អូ! ស្រុកនេះគេធ្វើជាងស្មិត គឺគេធ្វើឆ្នាំងស្ពាន់ឬពានធ្វើជាប្រដាប់ប្រើប្រាស់ផ្សេងៗ ដែលកើតពីសស្ពាន់ ឬដែក តើក្មួយត្រូវការចង់ចេះឬទេ ?

-បាទ ! វិជ្ជាទាំងនេះហើយដែលខ្ញុំស្វែងរកជាបំផុត សូមលោកមាមេត្តាអនុញ្ញាតឱ្យខ្ញុំចូលរៀនជាមួយផង

-មាមើលទៅរូបក្មួយឯងដូចជាមិនសមមកប្រកបការហត្ថកម្មដូច្នេះសោះ!

-ម្ដេចក៏មានប្រសាសន៍ថាមិនសម បើខ្ញុំមានរូបរាងមាំទាំយ៉ាងនឹងដែរ ។

-ពិតមែនតែរូបរាងមាំទាំ តែក្មួយមានកិរិយាបែបទន់ភ្លន់ គួរតែជាអ្នកស្រណុកកាយ ឬជាអ្នកទីក្រុង (វត្សាសើចគ្រាដែលឮតាម្ចាស់ផ្ទះពោលដូច្នេះ) ។

-ត្រង់ការទន់ភ្លន់បណ្ដូលមកពីខ្វះការហត្ថកម្មទេតើលោកមា មួយទៀតដោយខ្ញុំដឹងថាដូច្នេះហើយបានជាខំកាត់មករៀនការហត្ថកម្មនេះ ។



-អី! ក្មួយឯងយល់នេះប្រសើរហើយ. មាចាស់ជាងក្មួយ មាមានការពិសោធន៍ច្រើនជាង គឺមនុស្សយើងត្រូវតែស្វែងចំណេះដូច្នេះទើបហៅថាជាមនុស្សស្គាល់តម្លៃបស់មនុស្ស ។ តែនិយាយដល់រឿងនេះនាំឱ្យមារំលឹកឃើញដល់រឿងសំឡាញ់របស់មាម្នាក់ដែលធ្លាប់ថ្កុំថ្កើង ហើយបែរជាចុះក្រ ហើយថែមទាំងខ្ចាត់ព្រាត់ពីទីក្រុងទៀត ។

-យី ! សំឡាញ់លោកមាឈ្មោះអ្វី ? កាលគ្រាមុនមាធ្លាប់នៅឯទីក្រុងដែរឬលោកមា ?

-មាមិនធ្លាប់នៅឯទីក្រុងទេ ប៉ុន្តែមាមានមិត្តម្នាក់ស្គាល់គ្នាតាំងពីកម្លោះ កាលទៅធ្វើទាហានចេញទៅតទល់ទ័ពឯព្រំដែនប្រទេសយើងប៉ែកខាងកើត តែមិត្តមានោះ គេជាកូនអ្នកមានទ្រព្យច្រើនសម្បូរទមតឹកកេរ្តិ៍ពីឪពុក-ម្ដាយគេមិនដឹងយកទៅណានឹងអស់ តែគេត្រូវជាប់កំណែនជាមួយមាដែរ ។ លុះត្រឡប់មកពីបង្ក្រាបសត្រូវវិញ មាបានរំលឹកឱ្យគេស្វែងរកចំណេះវិជ្ជាអ្វីនឹងគេឡើយ តែគេឥតរវល់តាមសោះ គ្រាន់តែមកលេងនឹងភូមិមានេះក៏គេមិនមកលេងផង ព្រោះស្រុកព្រៃដូច្នេះ គេមិនចូលចិត្តទេ ។ វេលាក្រោយមក គេបានឡើងជាសេដ្ឋីគ្រប់គ្រងមតិ៍ក ។ ដល់បាន

កូនមួយ ប្រពន្ធក៏ស្លាប់ទៅទៀត កាលនោះមាបានទៅលេងនឹងគេម្តងដែរ ក្មួយអើយវាខុសគ្រូវគ្នាឆ្ងាយណាស់ពីរបៀបឯងនឹងគេ ។

-វាខុសគ្នាយ៉ាងណាខ្លះលោកមា ?

-ក្មួយអើយ ! កូនស្រីគេតែងខ្លួនដូចទេពអប្សរ មានភិលៀងថៃជូនអមអង្គដូចនាងអច្ឆរា ឯខ្លួនគេវិញក៏មើលតែព្រះ ឥន្ទ មានអ្នកបំរើប្រុស-ស្រី ក្មេង-ស្តាំ ឥតឃ្មើសទេ គ្រប់ពេល គ្រប់វេលា តែក្មួយអើយ!

-យ៉ាងណាលោកមា ?

-ហ៊ឺ !...ក្មួយអើយរាសីមនុស្សមិននៅទៀងប្រាកដទេ ជួនលិច, ជួនអណ្តែត បីដូចរាសីផ្កាយមានយប់ខ្លះភ្លឺខ្លាំង,យប់ខ្លះភ្លឺតិច ចំណេរតមកមិនយូរប៉ុន្មាន មាឮដំណឹងថាធ្លាក់ខ្លួនទៅជាក្រតោកយ៉ាក ខ្ចាត់ភ្លាត់ចេញពីស្រុកទេសថៃមទៀត ។

-ម្តេចឯចុះលោកមា ! ម្តេចក៏ចុះក្រអ្វីឆាប់ម្ល៉េះ ?

-មិនត្រឹមតែចុះក្រ ហើយខ្ចាត់ខ្ចាយពីស្រុកប៉ុណ្ណោះទេ ថែមទាំងមានឈ្មោះមិនល្អនឹងជាតិទៀត !

យី ! បើយ៉ាងនេះគាត់មិនជាអ្នកមានកិរិយាទុច្ចរិតឬ?

-ទេ !បើតាមមាពិនិត្យទៅ សំឡាញ់មានេះ មិនសមជា



អ្នកទុច្ចរិតសោះ ពិតមែនតែគេមានឫកជាអ្នកមានធំ តែឧស្សាហ៍ដំណាលលេងជាមួយមាជាញយថា គេនឹងរំលែកសម្បត្តិគេពាក់កណ្តាលដើម្បីជាជំនួយដល់ការកសាងមន្ទីរព្យាបាលរោគ នឹង មន្ទីរចិញ្ចឹមអ្នកក្រផង...

-សព្វថ្ងៃគាត់ទៅនៅស្រុកភូមិឯណាហើយលោកមា ?

-សព្វថ្ងៃមាឮគេថាមកនៅរហូតលើខ្នងភ្នំនេះដែរ តែមិនដឹងជាភូមិណា

-គាត់ឈ្មោះអ្វីទៅលោកមា ?

-ដល់ត្រង់នេះវត្សាសួរដេញដោលយ៉ាងរន្ថាន់ ព្រោះដូចជាប្រហាក់ប្រហែលខ្លះហើយ ។ ឯតាម្ចាស់ផ្ទះសោតវិញ គាត់មិនសូវលះសេចក្តីទេ ត្បិតគាត់នឹកអាមោក្ខនាធមីដល់សំឡាញ់ចាស់របស់គាត់ :

-ខ្លួនគេឈ្មោះគូ៉ាត. . . កូនស្រីឈ្មោះនាងភួងម៉ាឡៃ

-យី ! . . .

វត្សាលាន់មាត់ដោយសឹងតែមិនដឹងខ្លួនផង តែខំទប់ស្មារតីទើបងើបឡើងនិយាយមួយៗ តទៅទៀត ។

-មែនហ្ន៎ លោកមា ! រាសីមនុស្សមិនទៀងពិតមែន។

-ចុះម៉េចបានជាគ្រាន់តែឮឈ្មោះភ្លាមក៏ក្មួយលាន់មាត់ ភ្ញាក់សម្លេងយ៉ាងនេះ ក្មួយធ្លាប់ស្គាល់គាត់ដែរ ?

-បាទខ្ញុំមិនដែលស្គាល់ទេ តែខ្ញុំនឹកថាឈ្មោះគាត់អីល្អៗយ៉ាងនេះ មិនសមមកនៅក្នុងព្រៃភ្នំដូច្នេះសោះ ។

វេលាដែលបុរសពីរនាក់កំពុងសន្ទនានឹងគ្នានេះ មាននាងម្នាក់ កណ្ដៀតកញ្ជើដាក់ផ្តិលស្ពាន់ទើបសិតរួចថ្មីៗដើរឡើងមក:

-ម៉េចមល្លី ! ( តាម្ចាស់ផ្ទះសួរទៅកូនស្រីគាត់ដែលទើបតែឡើងមក ) ពួកជាងគេសិតផ្តិលហើយអស់ហើយ ?

-ចា៎ះ ! ហើយទាំងអស់ហើយពុក ( នារីពោលយ៉ាងញញឹមមកកាន់ឪពុក )

-អី រកកន្លែងរៀបទុកដាក់ស្រួលបួលទៅ ថ្ងៃស្អែកនេះត្រូវថ្ងៃពួកឈ្មួញអម្រែកមកទទួលយកទៅលក់ឯអង្គរហើយ ។

-ពួកជាងយើងសិតម្តងនេះបានផ្តិលល្អៗណាស់ពុក, ពុកមើលចុះ ! ( នាងដាក់កញ្ជើចុះហើយលើកផ្តិលដែលរលោងស្រិលបង្ហាញឪពុក ) ។

-យីអើ ! ល្អមែន, ចុះជើងពានគេមិនទាន់សិតហើយទេកូន ?



-ចា៎ះ មិនទាន់ហើយទេពុក គេកំពុងតែសិត ប្រហែលជាដល់ទៅស្អែកបានរួចទាំងអស់ ។

-ណ្ហើយ ! ជើងពានគេមិនសូវប្រញាប់ទេ ដល់កាលណារួចក៏មិនទាស់ដែរ ! នែមល្លី ! យកប៉ាន់ទៅឆុងទឹកថែមឱ្យពុកផងទឹកជិតអស់ពីប៉ាន់ហើយកូន ។

-ចា៎ះពុក !(នាងឆ្លើយទើបដើរចូលទៅឆុងទឹកតាមបំរើឪពុក) ។

គ្រានេះភ្ញៀវថ្មីក្នុងផ្ទះនេះឥតមានមាត់ថាអ្វីបន្តិចទេគេ ខំសង្កេតរូបនារីដែលគេទើបតែប្រទះឃើញក្នុងវេលានេះ ។

"យី ! នាងនេះមាត់ពាក្យបានណាស់ហ្ន៎ សមនឹងរូបរាងល្អស្រស់ប៉ុណ្ណោះផង មិនចាញ់នារីដួងចិត្តនៅភូមិរូងពស់ប៉ុន្មានទេ" វត្សានឹកសសើរក្នុងចិត្តតែម្នាក់ឯង តែខំព្យាយាមធ្វើកិរិយារម្យទមដូចដើម ។

* * *

# បំពូកទីប្រាំ

ចាប់តាំងពីថ្ងៃមួយនោះមកហើយ ដែលវត្សាត្រូវផ្លាស់ភេទពីកូនអ្នកមានស្តុកស្តម្ភ ទៅជាកូនជាងស្មិតបែបសាមញ្ញដូចគេដូចឯងឥតល្អៀង ។ ទោះបីការទាំងនេះលំបាកយ៉ាងណាដែលខ្លួនមិនដែលជួបប្រទះសោះក៏ដោយ ក៏ខំបង្ហាត់ខ្លួនឱ្យទាល់តែបានដូចកូនជាងដទៃ ហើយឱ្យបានជំនាញជាងគេថែមទៀតផង ។

កាលវេលាកន្លងផុតទៅចំនួនប្រាំបួនខែទៅហើយ, វត្សាកូនជាងពូព្រហ្មបានចេះស្ទាត់ខាងការស្មិត ហើយឆ្លៀតពេលខ្លះដែលទំនេរទៅរៀនចាក់កន្ទេល លើកជាគោមយ៉ាងល្អជាមួយនឹងពួក



ជាងស្រីៗ ទៀតផង ។ ជាងទាំងអស់ដែលមកធ្វើការនៅផ្ទះពូព្រហ្ម ប៉ែកខាងស្មិតក្តី, ប៉ែកខាងត្បាញកន្ទេលក្តី គេតែងនាំគ្នាឆ្ងល់ថាគេមិនដែលឃើញនាងកញ្ញាមល្លិកូនក្រមុំពូព្រហ្ម ស្តីនិយាយជាមួយនឹងវត្សាសោះ ទុកជាត្រូវធ្វើការអ្វីជាមួយគ្នា ក៏គ្រាន់តែធ្វើស្ងៀមៗ ទៅឥតស្តីនិយាយសោះ ។

ប៉ុន្តែយ៉ាងណាក៏ដោយ យើងគប្បីចាំថា ធម្មតាក្របីនឹងចេក, ក្អែកនឹងពងមាន់, មានសភាពទាក់ទងគ្នាយ៉ាងណា នារីក្រមុំនឹងប្រុសកំឡោះក៏យ៉ាងនោះដែរ ។

ព្រះអាទិត្យនិងព្រះចន្ទ ចេះតែយាងបន្តវេនគ្នាឥតបង្អង់ បីដូចជាជួយពង្រីកសេចក្តីព្យាយាមរបស់វត្សាដែលក្លែងឈ្មោះថា "សាឡុន " ឱ្យកាន់តែរីកធំឡើង ព្រមទាំងកិរិយានឹងធឹងឥតខ្ចោះដល់ភ្នែកអ្នកផងដល់ម្តងណាឡើយ ។ កិត្តិសព្ទផ្ទុះចេញពីមាត់អ្នករាល់គ្នានៅក្បែរខាងដែលសសើរពីកិរិយាមារយាទចៅកំឡោះយើងតែងតែហួរចូលទៅស្ថិតយ៉ាងខ្ជាប់ខ្ជួនក្នុងបេះដូងប្រមាត់នាងកញ្ញាបុត្រីពូព្រហ្មជានិច្ច ។ ចំណែកចៅកំលោះក៏តែងតែលួចគយគន់ដល់រូបរាងតរុណីនេះណាស់ដែរ ប៉ុន្តែមានហេតុមួយតែងមកដាស់ប្រាប់គេថា "ក្លិនរំដួលភ្នំគូលែន" ឬថា " នាងភ្នួងម៉ាឡៃបុត្រីតាគង្វាល"

ជារាល់ៗពេល ។ គេតែងជញ្ជឹងគិតជារឿយ ៗ " ឧត្តមគតិខ្លួនមានចំពោះតែរូបនាងភួងម៉ាឡៃប៉ុណ្ណោះ បានជាសុខចិត្តទ្រាំទ្រលំបាកវេទនាដើម្បីឱ្យបានសម្រេចឧត្តគតិនោះ ចុះឥឡូវបើបែរមករកគូថ្មីដូច្នេះតើសមឬទេ ? ម៉េចចាំបាច់មកធ្វើឱ្យលំបាកខ្លួនធ្វើអ្វី " ។ ទុកជារិះគិតយ៉ាងហ្នឹងក៏ដោយ នៅតែមានកូនចិត្តតូចមួយលបផុះពន្លកឡើងជ្រៀតត្បៀតនិងចិត្តមានះនេះដែរ ។

ថ្ងៃមួយជាឱកាសបុណ្យចូលឆ្នាំដែលអ្នកស្រុក អ្នកភូមិប្រជុំគ្នាធ្វើបុណ្យពូនភ្នំខ្សាច់ នៅក្នុងលានខាងមុខសាលាសំណាក់មួយ។ ឯពួកអ្នកស្រុកស្រី-ប្រុសចាស់ ៗ នាំគ្នាប្រជុំសូត្រនមស្សការរំលឹកគុណអស់ព្រះទេពទិសទសសោឡសសួគ៌នាយ ព្រមទាំងគោរព ព្រះរតនត្រ័យគុណកែវទាំងបី សុំឱ្យបានបរមសុខគ្រប់ៗគ្នា ។ ចំណែកពួកកំឡោះ-ក្រមុំ វិញ ក៏នាំគ្នាជួបជុំគ្នាលេងទាញព្រ័ត, ចោលឈូងតាម តែគេនឹកឃើញ ហើយនាំគ្នាសើចក្អាកក្អាយទ្រហឹងអឺងកង ។ មានជនចំពួកមួយទៀតដែលមិនចេះលេងអ្វីនឹងគេ ក៏នាំគ្នាត្រសងដើរកំសាន្តមើលគេឯងសឹងប្រដាប់ប្រាណយ៉ាងស្អាតស្អមផង ។

ថ្ងៃនេះនៅផ្ទះពូព្រហ្ម ឥតមានអ្នកណាច្រើនស្ថិតនៅទេ ត្បិតគេរវល់នឹងបុណ្យទាននោះគ្រប់ៗគ្នា មានតែនាងកញ្ញាមល្លីម្នាក់



ឯងប៉ុណ្ណោះ ។ ប៉ុន្តែបើគេសង្កេតក្នុងផ្ទះនេះឱ្យសព្វគ្រប់ គេនឹងឃើញចៅកំឡោះសាឡនអង្គុយឈ្ងោកក្បាលជ្រប់លើគ្រែតូចមួយក្នុងបន្ទប់ខ្លួនដែលនៅល្វែងខាងកើតឥតឮមាត់អ្វីសោះឡើយ ។ ជួនជានាងមល្លីនាងត្រូវដើរចូលទៅក្នុងបន្ទប់ឪពុកនាង ដើម្បីយកបារីដែលនាងទើបមូររួចទៅទុកក្នុងប្រអប់ជូនពុក ស្រាប់តែឮស្ងូរមនុស្សដកដង្ហើមធំ ។ នាងក៏លួចមើល តាមរន្ធជញ្ជាំងក្តារដែលមិនសូវជិតឃើញអ្នកកំឡោះនៅអង្គុយជ្រប់មុខម្នាក់ឯង ទើបនាងប្រថុយហាមាត់សួរដោយហេតុការណ៍ក្នុងខ្លួននាងបង្ខំជាខ្លាំង

-បង ! ម៉េចក៏មិនទៅលេងបុណ្យនឹងគេ ?

-...? ចៅកំឡោះឆ្ងល់ណាស់ ម៉េចក៏នាងក្រមុំមកនិយាយអីក្នុងបន្ទប់ជាមួយនឹងខ្លួនដូច្នេះ ឬជាមានភ្ញៀវណាមួយឡើងមក? តែដល់ឱនសង្កេតមើលតាមជញ្ជាំងទៅ ឥតយល់ថាមានមនុស្សសោះ តែក៏នៅមិនច្បាស់មិនហ៊ានតបសោះ ព្រោះនាងនឹងខ្លួនមិនដែលទាក់សំដីគ្នាម្តងណាឡើយ

-បងសាឡនអង្គុយធ្វើអីនេះម៉េចមិនទៅលេងបុណ្យ ? លុះឮសួរចេញឈ្មោះខ្លួនច្បាស់យ៉ាងនេះ ទើបដាច់ចិត្តឆ្លើយតបសំដីនាង :

-បាទ ! ខ្ញុំមិនបានទៅទេ ព្រោះដូចជាឥតសប្បាយអីសោះ បុណ្យនេះ ?

-ម៉េចក៏បងថាមិនសប្បាយ បុណ្យគេគគ្រឹកគគ្រេងសឹងអី

-បាទ ! គគ្រឹកគគ្រេងសម្រាប់តែអ្នកដទៃទេ ចំពោះរូបខ្ញុំនៅតែស្ងាត់ដូចធម្មតា ដោយចិត្តខ្ញុំជាអ្នកព្រួយច្រើន ។

-បងព្រួយពីអី ? បងគិតពីអីសព្វថ្ងៃ ?

-នាងសួរខ្ញុំយ៉ាងនេះ ខ្ញុំពិបាកជំរាបណាស់ប្រសិនជានាងមានប្រដាប់ទិព្វអ្វីមួយសម្រាប់ឆ្លុះមើលក្នុងចិត្តខ្ញុំ ទើបនាងឃើញច្បាស់ ។

-ហ្នឹងក៏មិនយល់ច្បាស់ដែរ បើខ្ញុំមិនមែនជាអ្នកមានបុណ្យបារមីអ្វី ឬជាអ្នកមានប្រដាប់ទិព្វសំរាប់ឆ្លុះមើលចិត្តបងសោះ តែខ្ញុំក៏អាចដឹងតែម្យ៉ាងថា: សព្វថ្ងៃបងគង់បានសុខសម្រាន្តជាមួយគ្រួសារខ្ញុំទៅហើយ

-បាទ ! ពិតមែន សព្វថ្ងៃខ្ញុំមិនដឹងជាបានអ្វីតបស្នងគុណឱ្យស្មើនឹងសេចក្តីសប្បុរសដែលគ្រួសារនាងបានចែកទានដល់ខ្ញុំទេ គ្រាតែមួយជីវិតខ្ញុំក៏មិនបានសងឱ្យរួចសារគុណនេះផងហ្នាំនាង ។

-មិនពិបាកសោះនឹងតបគុណ ! ជំពាក់គុណនេះ បើតាម



យោបល់ខ្ញុំ...

-ធ្វើយ៉ាងណានាង មេត្តាប្រាប់ខ្ញុំផងនឹងអាលខ្ញុំប្រព្រឹត្តទៅតាមលំអាននោះ ។

-យី ! បងប្រុសត្រឡាំង នៅតែនឹកមិនឃើញ នាងពោលរួចដើរចេញពីបន្ទប់ឪពុក ហើយចូលមកក្នុងបន្ទប់សាឡុនដោយមានផ្ទៃមុខញញឹមពព្រាយ :

-បន្ទប់ខ្ញុំឥតមានកន្លែងទទួលភ្ញៀវសោះ (អ្នកកំឡោះពោលដែលឃើញនាងចូលដល់ )

-កុំព្រួយ, រឿងនេះត្រូវបន្ទោសដល់ខ្ញុំជាម្ចាស់ផ្ទះនេះទៅវិញសមជាងដែលមិនបានយកប្រដាប់ប្រដាប្រើប្រាស់មកទុកឱ្យបង

-អូ អត់ទោស ! ខ្ញុំនិយាយនេះបីដូចជាខ្ញុំរកគូនចង់សុំប្រដាប់ប្រើប្រាស់ទៅហើយ ( ថាហើយអ្នកកំឡោះក្រោកឈរហើយបង្អោនខ្លួនបន្តិចអញ្ជើញនាងឱ្យអង្គុយចុះ )

-សូមនាងអញ្ជើញអង្គុយលើគ្រែនេះចុះ !

-កុំព្រួយ ! បងក៏ត្រូវតែអង្គុយខាងម្ខាងទៅដើម្បីនឹងបានជជែកគ្នាលេង . . . អង្គុយទៅកុំក្រែងបារម្ភអី !

-បាទ . . . មិនអីទេ. . . នាង !

-យុវា យុវតីជនទាំងពីរ ដូចជាកន្ទង់និងផ្កានៅក្នុងសួនតែមួយ ក៏ចាប់សន្ទនាគ្នាដោយទឹកមុខញញឹមប្លែកពីធម្មតា !

-យី,ឥឡូវបងដូចជាមិនសូវឃើញជិះសេះលេងដូចមុនសោះ

-នែ៎ ! ម៉េចក៏នាងដឹងថាខ្ញុំជិះសេះលេង ?

-កុំបាច់លាក់បង បងឯងចេញទៅណានៅក្នុងពេលយប់ថ្ងៃណាក៏ខ្ញុំដឹង !

-យ៉ាងហ្នឹងនាងយកចិត្តទុកដាក់លើរូបខ្ញុំណាស់ហ្ន៎ ? នាងសើចខឹកៗ បែបអៀនព្រោះដឹងខ្លួនថានិយាយនេះហួសបន្តិច តែខំកាត់អៀនបែរមុខនិយាយទៀត :

-ចាំមានថ្ងៃណា ខ្ញុំគិតសុំឱ្យបងបង្ហាត់ខ្ញុំឱ្យជិះសេះម្ដងលមើល ។

-កុំចង់រៀនអីនាង ជិះសេះវាមិនស្រណុកអីទេ ប៉ុន្តែខ្ញុំនិយាយយ៉ាងនេះហាក់ដូចជាខ្ញុំមិនចង់បង្ហាត់នាង . . .

-ណ្ហើយ ! ណ្ហើយ ! កុំភ័យៗ ខ្ញុំមិនមែនជាអ្នកចាំចាប់ថ្នាក់អីទេ ខ្ញុំគ្រាន់តែថាឱ្យមានជារឿងនិយាយឱ្យបានយូរនៅទេត្បិតខ្ញុំស្ដាប់សំដីបងដូចជាពិរោះគួរឱ្យចេះតែចង់ស្ដាប់ ។



-យី, ចុះខ្ញុំមានទៅរចនាពាក្យ ឱ្យល្អដូចជាជាងឆ្លាក់ជាងគំនូរឯណា ឬ ពាក្យនេះមានទៅពិរោះដូចកាព្យរបស់កវី ហើយមានសំលេងទន់ស្រួយដូចតាវ៉ៅ កាលណាបានជានាងថាពិរោះ

-វាមិនជូនរជីកហើយសួរក្រលួចដូចកវី ឬ ដូចតាវ៉ៅមែនតែជាតូរ្យតន្ត្រីសំរាប់ខ្ញុំដ៏ពិត ៗ ។

-ហួសចិត្តណាស់នាង អីក៏ដល់ម្លឹង !

-មានទៅហួសចិត្តអីបើគ្រាន់តែខ្ញុំថាប៉ុណ្ណឹង . . . .

-នែ ! នេះនាងគ្រាន់តែឮខ្ញុំនិយាយធម្មតា ចុះបើឃើញសំដីកាព្យឃ្លោងរបស់ខ្ញុំតែងទៀត . . .

-អូរ ! បងជាអ្នកតែងកាព្យផង ? មើល៍ ៗ តែងមួយឃ្លាឱ្យខ្ញុំស្ដាប់ផងមើល៍ ។

-ទេ ៗ ខ្ញុំថាលេងទេ ។

-យី កុំបាច់លាក់ ខ្ញុំស្មានដឹងស្រេចថាមនុស្សមានសំដីបែបបងនេះ ប្រសប់ណាស់ហើយខាងកំណាព្យកាព្យឃ្លោងនោះ ...ទៅ !

ធ្វើមួយឃ្លាទៅ ! ថ្លែងពីអ្វីក៏បានដែរឱ្យតែកាព្យ . . .

រត្សាអង្គុយអំអៀន ត្បិតមិនដឹងតែងពីអីបើមិនតែង

ដូចជាអន់ណាស់ ព្រោះខ្លួនបាននិយាយហួសទៅហើយៗ ងើយក្បាលមើលដំបូលមួយសន្ទុះទើបនិយាយ :

-នាងចាំស្តាប់  ខ្ញុំជូនតែមួយឃ្លាខ្លីទេ

-ចាំៈ ៗ ថាមក ៗ . . .

-ឱគូព្រេង វង្វេងព្រាត់ ភ្លាត់ទៅឆ្ងាយ បាត់រូបកាយណាយចិត្តចៅទៅហើយឬ . . . (វត្សាឈប់)

-អីទៅទៀត. មិនទាន់គ្រប់មួយឃ្លាផងប្រញាប់ឈប់ម្ល៉េះ?

-ទេនឹកមិនឃើញទេ . . . អូ ! អូ ! មែន :

. . បងស្រែកផ្តាំ ចាំថ្លាថ្លែង ក្រែងមិនឮ ឥតអង្គី ព្រីអង្គា វេទនាចិត្ត

. . ចប់ហើយនាង ! ចប់ហើយ ។

-អីយ៉ា ! កវីកំឡោះហើយតើនេះ ។

-កវីខ្ញុំចេះតែក្នុងពេលហ្នឹងទេតែក្រៅពីនេះសូន្យដូចយប់បរិយាកាសព្រៃភ្នំមិនទុកពេលឱ្យយុវជនសន្ទនាបានយូរទេ ស្រាប់តែឃើញពូព្រហ្មនិងមីងវត្ថភរិយាគាត់ កាន់ជើងពានធូបទៀនត្រឡប់មកពីទីសក្ការបូជាវិញភ្លាម ។ នាងកញ្ញាក៏ឃ្លាតចេញពីបន្ទប់នេះមួយរំពេចទៅដែរ ។



## ចំពូកទីប្រាំមួយ

សេះរបស់តក្សាបោលលឿនស្ទៅកាត់ព្រៃភ្នំ ផ្ទុកម្ចាស់លើខ្នងដោយមានទាំងស្ពាយសំពាយយ៉ាងធំ វេចសុទ្ធតែផ្តិលជើងពានប្រអប់ធ្វើពីស្ពាន់នឹងរម្មូរកន្ទេលកក់មួយល្ហូរ ដែលត្បាញលើកគោមយ៉ាងល្អស្រស់ ។ ផ្លូវលំបាកទាំងប៉ុន្មានលើខ្នងភ្នំ វត្សាចំណាំបានច្បាស់ឥតមានបារម្ភក្រែងវង្វេងផ្លូវទៀតទេ ។ គេជិះសេះបណ្តើរក្នុងចិត្តនឹកដល់ភ័ព្វវាសនារបស់គេបណ្តើរ :

" មិនគួរជាគ្នាស្ម័គ្រចិត្តលើ ឯងហើយឯងមិនស្រលាញ់ដូច្នេះសោះ ឱ! មល្លិ, ប្រហែលជាជាប់ចិត្តជំពាក់លើរូបខ្ញុំយ៉ាងណាទៅអេះ? បើគ្រាន់តែខ្ញុំចូលទៅលានាងៗ ស្រក់ទឹកភ្នែក អួលដើមក

ស្ដីលែងរួចទៅហើយ មល្ងី ! នាង ខំថែរក្សាកិរិយាមារយាទជាកុលធីតាមែនហ្ន៎ ។ ឱ ! ឱ្យខ្ញុំស្រឡាញ់នឹងនាងឯណាបាន បើខ្ញុំសន្យាក្នុងចិត្តថាមានតែនាងភូម៉ាខ្មៅមួយ ប៉ុណ្ណោះដែលត្រូវជាគូរបស់ខ្ញុំ ។ យ៉ាងណាទៅហ្ន៎ !នាងភូងម៉ាខ្មៅ តាគង្វាល... ប្រហែលនៅចាំមុខខ្ញុំបានទេ បើខ្ញុំទៅដល់ម្ដងនេះ... ពាក្យខ្ញុំនិយាយលេងជាមួយនាងនៅមាត់ស្ទឹង តើនាងនៅចាំបានខ្លះទេ ឬក៏មិនស្បិតលែងខ្ចីនឹកនាសោះទៅហើយ តែបើមើលទៅកិរិយានាងប្រហែលជាមិនមែនអ្នកសាវ៉ា, ជាអ្នកធ្វើឱ្យប្រុសបង់ចិត្ត, បង់ថ្លើមស្ដមខ្លួនដោយសារនាងទេ. . . យ៉ាងណាក៏ដោយក៏គួរតែទេវតាភ្នែកទិព្វ, មាត់ទិព្វផ្ញៀតទៅខ្សឹបប្រាប់នាងផងថា ខ្ញុំនៅចងចិត្តជំពាក់លើឆោមយង់របស់នាងជានិច្ច បើប្រែជាមិនសម្រេចបំណងទេ ខ្ញុំត្រូវតែទៅសាងបព្វជាស្វែងរកកងការកុសលទៅជាតិមុខវិញ ប្រសើរជាងរស់នៅដោយឥតរូបនាងនៅក្បែរ... " ភាពស្រមៃ,ភាពរវើរវាយទាញយកវិញ្ញាណចៅកំឡោះផ្សងព្រេងឱ្យរសាត់ទៅឆ្ងាយសែនឆ្ងាយ ភ្លេចនឹកនាពីការស្រេកឃ្លានអស់ទៅហើយ ឯខ្សែរបង្ហៀសេះ ចេះតែញាក់តម្រង់ផ្លូវឥតឈប់ឈរ, កែងជើងក៏ចេះតែគោះឱ្យសញ្ញាប្រាប់ជំនិះឱ្យរឹតតែលឿនឡើងៗគ្មានបង្អង់ ។ សេងសូរិយថ្លាត្រចះព្វជ័ន



ភាល័យបំផាយរាជរថលឿនលយលើសរត្សាទៅទៀត ។ មិនយូរប៉ុន្មាន ស្រាប់តែយាងដល់ពាក់កណ្ដាលពិភពលោកមួយរំពេច ។ អ្នកផ្សងព្រេងយើងលោតចុះពីអាជានេយ្យចំ ត្រង់ដើមជើងចាបមួយធំក្នុងភូមិរូងពស់ ។ ប្លែកមែន, ឥតឃើញខ្ទមតាគង្វាលដូចគ្រាមុនសោះ ឯស្នាមក៏សឹងតែបាត់សូន្យទៅហើយ បែរជាមានស្មៅដុះខ្នាន់ខ្នាប់ជំនួសរូបខ្ទមទៅវិញ ។ រត្សា ជួបប្រទះនឹងការអស់សង្ឃឹម, ឈរគ្រវីក្បាល, ជ្រប់មុខតែឥតចេញស្ដី ក៏ចាប់ទាញសេះមកលោតផែលបំផាយតម្រង់ទៅមើលកន្លែងមាត់ស្ទឹងដែលខ្លួនបានជួបចំអែចំអន់លេងជាមួយនារីដួងចិត្តពីគ្រាមុននោះ ។

ឱ ! គួរអនិច្ចា, រដូវវស្សាទឹកជំនន់ហូរច្រើនពេញប្រៀបស្ទឹងលើសគ្រាមុន តែឥតយល់ស្រមោល ឬ ស្នាមអ្វីជាដានគួរឱ្យងាយរកសោះ ដើមឈើមាត់ស្ទឹងនៅគង់ដូចដើម, ដុំថ្មដែលខ្លួនអង្គុយមើលមុខនាងក៏គង់នៅដដែល ប្លែកតែត្រង់ស្នាមផ្លូវដើររលប់បាត់អស់ ដ្បិតគ្មានមនុស្សដើរទុកពេលឱ្យស្មៅដុះជិតទៅហើយ ។ ត្រង់នេះ, ឱ្យរត្សាសន្និដ្ឋានក្នុងចិត្តថា " នារីជាបេះដូងខ្លួនបានចាកពីភូមិនេះយូរហើយ" ។

ចៅកំឡោះលែងសេះឱ្យស៊ីស្មៅ រួចមកអង្គុយលើដុំថ្ម

ដដែលតាំងគិតក្នុងចិត្តដោយទឹកមុខស្រពាប់ស្រពោនឥតឧបមា :

" . . ថ្ងៃនេះហើយដែលខ្ញុំអង្គុយក្បែរនាង, ម្លប់ឈើនេះហើយដែលខ្ញុំជ្រកជាមួយនាង ចុះឥឡូវម៉េចក៏មិនឃើញនាងសោះ ឃើញតែទឹកជំនន់ហូរគ្របាញ់ទៅវិញ ។ ឯណាមុខស្រស់ញញឹមក៏បែរឃើញតែធម្មជាតិស្រស់បំព្រង ឯណាសក់ក្បាលសំផុលតាមខ្យល់ក៏ឃើញតែស្លឹកឈើបក់រវិច, ឯណាមិនឮសួរសំដីសើចនិយាយតបនឹងខ្ញុំប្រែជា ឮសំលេងសព្ទសត្វយំទ្រហឹងជំនួសវិញដូច្នេះ... ខ្សែទឹកហូរខ្មាញ់ នេះតើនាំខ្លួនខ្ញុំឱ្យទៅជួបនឹងនារីឆ្នើមចិត្តខ្ញុំបានទេ.. ម៉េចក៏ទឹកចេះតែហូរចុះទៅៗយ៉ាងនេះ ម៉េចក៏មិនហូរច្រាសឡើងមកវិញ ដើម្បីប្រាប់ដំណឹងខ្ញុំផងតើនាងឃ្លាតពីនេះ ទៅនៅឯតំបន់ណា ?

នឹកក្នុងចិត្តរួចចៅកំឡោះក្រោកឡើងដើទៅបេះផ្កាបានបីទង ហើយបណ្ដែតតាមទឹកដោយពោលរងំៗផង : សូមឱ្យផ្កាអណ្ដែតទៅដល់ដៃនាងគ្រាន់ជាដំណឹង ឱ្យនាងដឹងថាខ្ញុំមកដល់ទីនេះហើយ គ្រាន់ធ្លាក់ដល់ទឹកភ្លាម បុប្ផាបីទងរសាត់លឿនស្ងៅឥតមានរារង់នាំឱ្យវត្សាសង្ឃឹមក្នុងចិត្តថា ផ្កាមុខជាទទួលបណ្ដាំខ្លួនហើយ ។



រួចពីនេះ វត្សាដើរឡើងមកពីទីដែលធ្លាប់បានមនោរម្យពីគ្រាមុន ហើយជាទីខ្លោចផ្សាក្នុងវេលានេះដោយចិត្តក្ដុកក្ដួលពន់ប្រមាណ ។ គេដឹកសេះបណ្ដើរនឹកក្នុងចិត្តបណ្ដើរ :

អីមែនហ្ន៎ ព្រះកាមទេពមានសរប្រកបដោយពិសខ្លាំងមែនតែងញាំញីដួងចិត្តយុវជនឥតមានប្រណីឡើយ ទុកជាខំតាំងចិត្តឱ្យម៉ឺងម៉ាត់យ៉ាងណា ក៏ជៀសមិនរួចពីសំណាញ់ព្រះកាមទេពដែរ ព្រោះសំណាញ់នេះមាននាទីធំណាស់, ធំឥតទីដៅរហូតទៅដល់ព្រះពុទ្ធអង្គគង់ព្រះមហាកាមទេពយកមុខសរទៅជន្ទកំហែងម្ដងៗដែរ... ចំណង់បើជនសាមញ្ញទៀត ?... ភ្លូងម៉ាខ្សែ! នាងមិនគួរឃ្លាតចាកពីទីនេះដោយគ្មានទុកដានបន្តិចបន្តួចឱ្យខ្ញុំដូច្នេះសោះ នេះហេតុតែនាងមិនទាន់ដឹងពីគំនិតខ្ញុំដែលព្រាងទុកជាស្រេចសម្រាប់ពេលណាដែលបានរួបរួមជីវិតជាមួយនាង ! ឬមួយជានាងត្រូវឪពុកទុកដាក់ឱ្យមានគូស្រករទៅហើយ ប៉ុន្តែប្រសិនជាយ៉ាងនេះមែន ក៏ខ្ញុំឥតតូចចិត្តដែរ តែសុំនាងឱ្យដំណឹងដល់ខ្ញុំជាមុន នោះខ្ញុំនឹងនឹកថាជាគ្រោះអភ័ព្វពីបុព្វេទៅវិញចុះ...

សេចក្ដីគិតក្នុងចិត្តរបស់វត្សានៅវេលានេះមិនដឹងជាមានប៉ុន្មានចំពូកទេ ព្រោះហេតុដែលត្រូវគិតអាចប្រៀបបាននឹងពន្លក

ស្មៅលេចប៉ិចឡើងពីដីដែលគេជំរះទើបរួចបី-បួនថ្ងៃ ។ មិនទាំងដឹងខ្លួនផង, ស្រាប់តែទៅដល់លំនៅមួយដែលមានយាយចាស់ម្នាក់កំពុងក្រងស្បូវ ។

ចៅកំឡោះយើង ក៏ដើចូលទៅបន្ទន់ខ្លួនចំពោះមុខយាយជរា :

-លោកយាយសូមមេត្តាអត់ទោស !

យាយចាស់ងើបឡើងភ្ញាក់ស្រឡាំងកាំង :

-រកអីចៅ !

-បាទ ! លោកយាយមានដឹងថាពូម្នាក់ដែលកាលមុនសង់ខ្ទមនៅក្រោមដើមដើបចាបនុំះឥឡូវទៅនៅឯណាវិញទៅ :

-អូ ! គាត់ដែលចិញ្ចឹមមេគោហើយមានកូនស្រីម្នាក់នោះឬ?

-បាទ ! ហ្នឹងហើយលោកយាយ !

-អូ ! តានោះគាត់ទៅនៅឯជិតព្រះធំទៅហើយ ព្រោះគាត់ត្រូវការទៅរកធម៌អាថ៌ជាមួយលោកធុតង្គមួយអង្គ ដែលមកគង់នៅទីនោះ

-អូ !គាត់រុះរើខ្ទមយូរហើយ ?



-ប្រហែលជាងបីខែហើយចៅ, ឥឡូវគាត់ឥតរវល់នឹងសត្វនឹងធាតុអ្វីទៀតទេ គាត់ទុកដាក់ស្រេចតែលើកូនស្រីគាត់ទៅហើយ ។

-យ៉ាងនេះ  ខ្ញុំជំរាបលាហើយលោកយាយ !

-អីបន្ទាន់ម្ល៉េះចៅ, តើចៅរកតានោះមានការអ្វី ?

-បាទ ! ឥតការអ្វីទេ ខ្ញុំធ្លាប់ស្គាល់គាត់យូរមកហើយ

-អើ អញ្ជើញចុះបើប្រញាប់

ចៅកំឡោះរីកមុខថ្លាចិត្តឥតគណនាដោយបានដំណឹងយ៉ាងគាប់ចិត្តនេះ ។ កម្លាំងសេះបោះពួយដូចហោះកណ្ដាលអាកាស ។ មិនយូរទេ, ចៅកំឡោះយើងក៏បានដល់កន្លែងព្រះធំភ្លាម។ គេចុះពីសេះតាំងពីចម្ងាយ ហើយស្ពាយសំពាយធំៗនោះចូលទៅកូនខ្ទមមួយ សង់ប្របប្ញស្សីមួយគុម្ព ទៀបផ្ទាំងថ្មជាទីដម្កល់ព្រះពុទ្ធបដិមាករ ។ ក្រឡេកភ្នែកពីនាយ វត្សាឃើញតាគង្វាលអង្គុយកាន់ស្លឹករឹតកំពុងចារយ៉ាងផ្ចៀងផ្ចាត់ ឃើញតែចុងញាប់ស្មេញឥតរវល់នឹងមើលនាយអាយសោះ :

-ជំរាបសួរលោកមា ! ( វត្សាគោរព )

-អើ . . . ( តាយើងដាក់ដែកចារនិងស្លឹករឹតចុះ បាំងដៃ

មើលបញ្ឈាក់ភ្នៀវគាត់ )

-លោកមាចាំមុខខ្ញុំបានទេ, គឺខ្ញុំហើយដែលវង្វេងផ្លូវមកសម្រាកនឹងផ្ទះមាពីប៉ុន្មានខែមុននោះ ហើយខ្ញុំបានទាំងអញ្ជើញលោកមាទៅឯទីក្រុងផង ។

-អូ មានឹកឃើញហើយ ក្មួយឯងហើយតើដែលមកដណ្ដឹងកូនស្រីមា !

-បាទខ្ញុំហ្នឹងហើយលោកមា . . .កាលនោះមាបានឱ្យដំបូន្មានយ៉ាងប្រសើរដល់ខ្ញុំ នាំឱ្យខ្ញុំខំស្វះស្វែងរកលុះត្រាបានចេះវិជ្ជាប្រចាំជីវិតជាស្រេច. ខ្ញុំចេះខាងជាងស្មិតយ៉ាងស្ទាត់ មិនតែប៉ុណ្ណោះខ្ញុំចេះការរាយរងឯទៀតច្រើនផង ដូចយ៉ាងចាក់ក្បាញកន្ទេលលើកគោមជាដើម, លោកមាមើលចុះ នេះហើយជាស្នាដៃរបស់ខ្ញុំ (វត្សាស្រាយសំពាយរើយកវត្ថុខ្លួនមកបង្ហាញតា )

តពីនេះវត្សាចាប់ពណ៌នា តាំងពីដើមដល់ចប់អំពីដំណើរខ្លួនចេញស្វែងចំណេះនេះ ត្បិតជាន់សម័យនោះគ្មានវិជ្ជាអ្វីប្រសើរជាជាងរបរជំនាងនេះទេ ។

តាជរាស្ដាប់ដោយមុខញញឹមគាប់ចិត្តនឹងសេចក្ដីមានះ



នឹងព្យាយាមក្នុងការស្វែងវិជ្ជានៃអនាគតកូនប្រសារគាត់ ។ ក្នុងវេលានោះ នាងភួងម៉ាឡៃជិះលើខ្នងគោមួយគៀងគោឯទៀតតម្រង់បញ្ចូលក្រោល ។ នៅដៃនាងកាន់ផ្កាមួយទង ឯភ្នែកនាងសំឡឹងពិនិត្យផ្កានោះឥតដាក់ភ្នែកដោយសង្ស័យក្នុងចិត្តជាខ្លាំងថា " ផ្កានេះអណ្ដែតមកមានសភាពស្រស់ញញឹមដូចផ្កាដែលនាងរើសរបស់ប្រុសម្នាក់កាលពីថ្ងៃមុន " ។ កំពុងតែមមៃក្នុងចិត្ត នឹងក្រឡេកមកខ្ទមនាងក៏ឃើញច្បាស់រូបកំឡោះដដែលនោះមកទៀតមែន ។ នាងលោតចុះពីខ្នងគោ ដើរចេញមួយរំពេច ។

-ម៉េចសុខសប្បាយទេ នាងអូន ?

-ចាំ៖ !... (នាងឆ្លើយទៅទៀតមិនរួច បានតែប៉ុណ្ណេះក៏ដើរហួសដោយក្ដីអៀនខ្មាស់របស់និស្ស័យខេមរនារីយើង) ។

* * *

## ចំពូកទីប្រាំពីរ

ក្នុងថ្ងៃនោះនៅគេហស្ថានរបស់សេដ្ឋីជាមាតា បិតា វត្សាសប្បាយរីករាយពូតែស្ទូរសើចទ្រហឹងអឹងកង ។ ត្បិតគេទើបតែបានជួបជុំ នឹងកូនប្រុសគេ ដែលឃ្លាតទៅបាត់ដំណឹងសូន្យប្រហែលជិតមួយឆ្នាំហើយ។ មិនតែប៉ុណ្ណោះ គេសប្បាយដោយបានទទួលភ្ញៀវពីរនាក់ទៀតគឺ តាអតីតសេដ្ឋីគូរ៉ាត ឬអតីតាគង្វាលគោ និង នាងកញ្ញាភួងម៉ាខ្សៃនារីផ្ញើមរបស់វត្សា ។

វិវាហមង្គលរវាងនាងកញ្ញាខ្នងភ្នំនិងបុត្រសេដ្ឋីសុផ្កាក់ បើកឆាកឡើងឧឡារិកគគ្រឹកគគ្រេងពន់ប្រមាណ ។ នាហ្មឺនមុខ



មន្ត្រីគ្រប់តំណែងក្នុងរាជធានីក៏បានអញ្ជើញជាកិត្តិយសមកជួបជុំក្នុងឱកាសនេះដែរ ។

អតីតសេដ្ឋីបិតានាងភួងម៉ាខ្សៃ ដែលពីដើមមកមិនចង់ឱ្យជួបមុខនឹងគេឯងសោះ ឥឡូវក៏ជៀសមិនបានត្រូវតែគាត់ចេញមកគួរសមរាក់ទាក់នឹងភ្ញៀវគ្រប់ឋានៈតាមមេត្រីភាពដ៏ខ្ពង់ខ្ពស់ ។

ឯកិត្តិសព្ទល្អប្រសើរ របស់គាត់ដែលធ្លាប់នៅគ្រប់គ្រងតំបន់ស៊ីសូផុននោះ ឥឡូវក៏ខ្ចរខ្ចាយឡើងម្តងទៀតដោយសារមាត់ភ្ញៀវណាដែលគេធ្លាប់ស្គាល់ទាក់ទងជាមួយគាត់យូរឆ្នាំហើយ។ ឯការពិតក៏កាន់តែផុសឡើងបន្តិចម្តងៗ រហូតដល់មានអ្នកណាដែលធ្លាប់តែឮល្បៀងៗថាគាត់ជាមនុស្សក្បត់ពីថ្ងៃមុនខិតខំឱ្យបខ្សៀវសួរបញ្ជាក់គ្នីគ្នាត្រាតែដឹងច្បាស់ថា "តាចាស់នេះជាមនុស្សស្លូតត្រង់ពិត តែដោយមានមនុស្សលបពោលបង្កាច់ ហើយឡើងទៅក្រាបបង្គំទូលព្រះរាជាផងដើម្បីដណ្តើមយកនាទីជាស្តេចក្រាញ់នៅខែត្រស៊ីសុផុននោះ ។

ក្រោយពីកិច្ចអាពាហ៍ពិពាហ៍មិនយូរឡើយ ដំណឹងពិតប្រាកដនេះបានជ្រាបដល់ព្រះបាទយសោវ័ន្ទ ។ ព្រះអង្គក៏ទ្រង់ត្រាស់បញ្ជាឱ្យរាជអាមាត្រមកអញ្ជើញអតីតរូបសេដ្ឋីគូរ៉ាត ដើម្បីឡើងទៅ

កាន់ព្រះគំនាល់ព្រះអង្គនឹងទ្រង់ត្រាស់សួរបញ្ជាក់ការឱ្យច្បាស់លាស់។

ចំនួនដប់ថ្ងៃតមក នៅគេហស្ថានលោកសេដ្ឋីសុផ្កាមានពិធីលៀងភ្ញៀវយ៉ាងគគ្រឹកគគ្រេងម្តងទៀតគឺជាឱកាសចៅរត្សាទទួលនូវឋានន្តរសក្តិជាស្តេចក្រាញ់នៅខេត្តស៊ីសុផុនដែលព្រះរាជាទ្រង់ប្រោសព្រះរាជទានតែងតាំងជាមតិកដំណរពីឪពុកក្មេកដែលគាត់ត្រូវសុំព្រះរាជានុញ្ញាតព្រះនរបតីទៅសាងភ្នូសសន្សំសីលទាននៅលើខ្នងភ្នំវិញ ។ ចាប់រហូតពីគ្រានោះមករត្សា និង ភរិយាសម្លាញ់ក៏បានសុខសាន្តគ្រប់កាល គេបាននាំប្តីប្រពន្ធបរទេះរថទឹមសេះ ដោយមានបាវព្រាវជាបរិវារហែហមផង តម្រង់ទៅកាន់ភូមិរបស់ពូព្រហ្មដើម្បីសួរសុខទុក្ខ នឹងថ្លែងសេចក្តីរលឹករឿងខ្លួន ។ គ្មានអ្វីសប្បាយលើសលែងជាងការដែលគេជួបជុំគ្នានេះទេ ត្បិតកាលដើមគេធ្លាប់តែឃើញរូបនេះឈ្មោះសាឡុនជាកូនជាង ឥឡូវប្រែទៅជាឈ្មោះរត្សាងារជាស្តេចក្រាញ់ទៅវិញ ។ រត្សាក៏ឆ្លៀតពេលនេះពណ៌នាឱ្យភរិយាស្តាប់ពីហេតុដើមរហូតដល់ចុង ។ ជួនជាពេលនោះពូព្រហ្ម គាត់ឃាត់ឱ្យរងចាំបីថ្ងៃទៀត ដែលជាឱកាសរៀបមង្គលការនាងមល្លីបុត្រីគាត់ផង ឧកញ៉ារត្សាយើងក៏ឆ្លៀតរងចាំដោយសេចក្តីរីករាយជាអនេក ត្បិតបានមកជួបប្រទះនឹងឱកាស



មានមង្គលនេះ ។ លុះការរួច ឧកញ៉ាស្តេចក្រាញ់ថ្មីក៏បានអញ្ជើញពូមីងព្រមទាំងមល្លី និងស្វាមី មកនៅសុខសំរាន្តឯខេត្តស៊ីសុផុនជាមួយគ្នារហូតទៅ ។

................................................................................

................................................................................

និយាយមកដល់ត្រង់ចប់នេះ លោកតាអ្នកនិទានរឿងឱ្យខ្ញុំស្តាប់ បានងាកបែរទៅពិសាទឹកអស់កន្លះសៀន ទើបបញ្ជាក់ប្រាប់ខ្ញុំទៀតថា :

រឿងដែលតានិទាននេះ មិនដឹងជាពិតឬមិនពិតទេ តាបានចាំតៗ មកពីចាស់ ៗ ដែលតែងនិទានរឿងនេះចែកគ្នីគ្នាស្តាប់នៅពេលណាដែលគាត់ជួបគ្នា ។ ដូចជាចៅយល់ស្រាប់ហើយតាមផ្ទៃរឿងនេះ ។ តាឃើញថាវាជារឿងប្លែកពីមនុស្សធម្មតាណាស់ ប៉ុន្តែវាទាស់តែប្លែកយ៉ាងហ្នឹងហើយបានគេនាំគ្នចងចាំមក ។ ឯត្រង់ខាងចុងរឿង យើងឃើញតួក្នុងរឿងនេះទាំងអស់ សុទ្ធតែសម្រេចផលដូចប្រាថ្នា ។

ខ្ញុំជំរាបលាតានោះបន្តរដំណើរទៅមុខទៀត ដោយចងចាំជាប់ទាំងរឿងរ៉ាវនោះមកតាមខ្លួនផង ។

**- ចប់ -**

សូមរង់ចាំអានជាបន្តនូវរឿង:
" **ទឹកទន្លេសាប** " របស់អ្នកនិពន្ធ **គឹម ហារ៉ា** ដែលជា
ប្រលោមលោកបែបមនោសញ្ចេតនា នាទសវត្ស
ឆ្នាំ ១៩៣៩ ។ ដែលនឹងចេញផ្សាយពីបណ្ណាគារដដែល
ក្នុងពេលឆាប់ៗខាងមុខនេះ !!!